១០៨ លោក **សៅ ប្រូស** ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ តាំងក្រសាំង

១០៩ លោក **ពៀម ម៉ុនណារឿន** ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ តាំងក្រសាំង

**ប្រការ ២.**~ នាយកខុទ្ទកាល័យ ប្រធាន មន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ទីចាត់ការគយ និងរដ្ឋាករ និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ២៥៦ នបប្រក.សហវ**

**ស្តីពីការបង្កើតក្រុមការងារអាស៊ានអមទីចាត់ការគយ និង រដ្ឋាករ**

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស ១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម នស.រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**ប្រការ ១.**~ បង្កើតក្រុមការងារមួយអោយទទួលបន្ទុកផ្នែកការងារអាស៊ានទៅទីចាត់ការគយ និង រដ្ឋាករ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១_លោក | **សៀង ឈុនឡី** | នាយករងទីចាត់ការគយ និង រដ្ឋាករ | ប្រធាន |
| ២_លោក | **ជា ហាក់** | អនុប្រធានការិយាល័យវិវាទនិងច្បាប់ | អនុប្រធាន |
| ៣_លោក | **ម៉ែន សំអាត** | អនុប្រធានការិយាល័យត្រួតពិនិត្យ ទទួលបន្ទុកអចិន្ត្រៃយ៍ | អនុប្រធាន |
| ៤_លោក | **គេ សុមុនី** | ឋានៈអនុប្រធានស្នាក់ការគយនិងរដ្ឋាករ | សមាជិក |
| ៥_លោក | **គីម ខួន** | ឋានៈអនុប្រធានស្នាក់ការគយនិងរដ្ឋាករ | សមាជិក |
| ៦_លោក | **ជួន ប៊ូលីន** | មន្ត្រីរាជការគយនិងរដ្ឋាករ | សមាជិក |
| ៧_លោក | **ជា សារ៉ាត់** | មន្ត្រីរាជការគយនិងរដ្ឋាករ | សមាជិក |
| ៨_លោក | **ម៉ុក ឃួត** | មន្ត្រីរាជការគយនិងរដ្ឋាករ | សមាជិក |
| ៩_លោក | **ញៀត សម្បត្តិ** | មន្ត្រីរាជការគយនិងរដ្ឋាករ | សមាជិក |
| ១០_លោក | **ហេង ចំន្ទ** | មន្ត្រីរាជការគយនិងរដ្ឋាករ | សមាជិក |
| ១១_លោក | **ប្រាក់ សុម៉េត** | មន្ត្រីរាជការគយនិងរដ្ឋាករ | សមាជិក |

**ប្រការ ២.**~ ក្រុមការងារអាស៊ានមានភារកិច្ចដូចតទៅ ÷

១–ស្រាវជ្រាវរៀបចំឯកសារពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ទីចាត់ការគយនិងរដ្ឋាករក្នុងការ ត្រៀមចូលជាសមាជិកអាស៊ាន ។

២–រៀបចំចងក្រងស្ថិតិទំនិញនាំចេញ សំរាប់ជាមូលដ្ឋានក្នុងការរៀបចំ Product List ដែលត្រូវបញ្ចូនក្នុង CEPT SCHEME នៃ AFTA ។

៣–សំរបសំរួលការងារជំនាញជាមួយនាយដ្ឋានអាស៊ាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងអង្គភាព អាស៊ានអមក្រសួងពាក់ព័ន្ធដទៃទៀត ។

៤–តាមដានកិច្ចសហការជាមួយរដ្ឋបាលគយ នៃប្រទេសដែលជាសមាជិកដទៃទៀតរបស់សមាគមអាស៊ាន ។

**ប្រការ៣.~** ក្រុមការងារអាស៊ានត្រូវបានទទួលភារកិច្ចដូចក្នុងប្រការ ២ បន្ថែមពីលើភារកិច្ចរបស់សមាជិកនៃក្រុមនេះដែលកំពុងមានបច្ចុប្បន្ន ។

**ប្រការ ៤.~** ក្រុមការងារនេះមានសិទ្ធិអញ្ជើញមន្ត្រី និងភ្នាក់ងារគយក្នុងអង្គភាព , ការិយាល័យ , សាខាទាំងអស់ដែលមានការពាក់ព័ន្ធអោយចូលរួមធ្វើការងារ ការរៀបចំឯកសារការប្រជុំពិភាក្សាតាមការជាក់ស្តែង ។

**ប្រការ ៥.~** នាយកខុទ្ទកាល័យ ប្រធាន មន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានក្រុមការងារអាស៊ាន នាយកទីចាត់ការគយ និង រដ្ឋាករ និងសាម៉ីខ្លួនត្រូវទទួលអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ២៥៧ ប្រក.សហវ.គរ**

**ស្តីពីការគ្រប់គ្រងលើទំនិញនាំចូល**

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល